ក

## មាតិកា

## I. ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៩-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៤៤ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះមហាឧបាសកព្រឹទ្ធាចារ្យ,លោកជំទាវឧកញ៉ា និង អស់លោក ចំនួន ០៨ រូប ៦៤១៩

១៩-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៤៥ ស្តីពីការតែងតាំងលោក សៅ សារូប ជា ឧកញ៉ា ៦៤២០

១៩-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៤៦ ស្តីពីការតែងតាំងឥស្សរជនចំនួន ០៤ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ៦៤២១

២១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៤៧ ស្តីពីការតម្លើងឋានៈជូនឯកឧត្តម ម៉ៅ សុខន្ធារា ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ និង តែងតាំងឯកឧត្តម ចំនួន ០២ រូប ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី ២ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៦៤២២

២១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៤៨ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ លោកឧកញ៉ា,ឯកឧត្តម,លោកជំទាវ,អស់លោក និងលោកស្រី ចំនួន ២២ រូប ៦៤២៣

២១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៤៩ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះឯកឧត្តម នាយឧត្តមសេនីយ៍ ឌុល គឿន ៦៤២៤

២១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥០ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម, លោកជំទាវ,លោកឧកញ៉ា,អស់លោក និង លោកស្រី ចំនួន ១១៤ រូប ៦៤២៥

២១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥១ ស្តីពីការប្រោសព្រះរាជទាន ចំពោះ ឯកឧត្តម និង អស់លោក ចំនួន ០៦ រូប នូវគ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ៦៤២៨

២១-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥២ ស្តីពីការប្រោសព្រះរាជទាន ចំពោះលោក គួច ម៉េងលី នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ៦៤២៩

២៤-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥៣ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម,លោកឧកញ៉ា,អស់លោក និង លោកស្រី ចំនួន ២២ រូប ៦៤៣០
២៤-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥៤ ស្តីពីការតែងតាំងឯកឧត្តម ឆេង ម៉ុន្ថា ជាទីប្រឹក្សា អមក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ មានឋានៈស្មើ អនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៤៣១
២៤-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥៥ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម,លោកឧកញ៉ា, និងអស់លោក ចំនួន ៣០ រូប ៦៤៣២
២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥៦ ស្តីពីការតែងតាំងលោក អ៊ុំខ សុចិត្ត ជា ឧកញ៉ា ៦៤៣៣
២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥៧ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០២ រូប ជាទីប្រឹក្សា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី ៤ មានឋានៈស្មើ រដ្ឋលេខាធិការ ៦៤៣៤
២៧-៨-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៨០៩/៨៥៨ ស្តីពីការតែងតាំងឯកឧត្តមចំនួន ០៣ រូប ជាទីប្រឹក្សា សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី ៤ បន្ថែមលើមុខងារបច្ចុប្បន្ន ៦៤៣៥

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៦-៨-២០០៩ -អនុក្រឹត្យលេខ ១៣៩ អនក្រ.បក ស្តីពីការជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១ ៦៤៣៦
២៨-៨-២០០៩ -អនុក្រឹត្យលេខ ១៤០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦៤៤២
៣១-៨-២០០៩ -អនុក្រឹត្យលេខ ១៤១ អនក្រ.បក ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យ យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ៦៤៤៤
៣១-៨-២០០៩ -អនុក្រឹត្យលេខ ១៤២ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៦៤៥០
១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៤៥២
១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣១៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៤៥៣
១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣១៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៤៥៤
១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣១៨ អនក្រ.តត ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ៦៤៥៥
១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣១៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៤៥៦

១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣២០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៤៥៧

១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣២១ អនក្រ.តត ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៤៥៨

១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣២២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៤៥៩

១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣២៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីសង្ឃ និង មន្ត្រីរាជការ ៦៤៦០

១២-៨-២០០៩ -អនុក្រឹត្យលេខ ១៣២៤ អនក្រ.តត ស្ដីពីការផ្ទេរភារកិច្ច និង តែងតាំងមុខតំណែងនាយនគរបាលជាតិ ៦៤៦២

១៣-៨-២០០៩ -អនុក្រឹត្យលេខ ១៣២៥ អនក្រ.តត ស្ដីពីការជូនគ្រឿងឥស្សរិយយស សុវត្ថារា ៦៤៦៣

១៣-៨-២០០៩ -អនុក្រឹត្យលេខ ១៣២៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៤៦៥

១៣-៨-២០០៩ -អនុក្រឹត្យលេខ ១៣២៧ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៤៦៧

១៣-៨-២០០៩ -អនុក្រឹត្យលេខ ១៣២៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៤៦៨

១៤-៨-២០០៩ -អនុក្រឹត្យលេខ ១៣២៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៤៦៩

១៤-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣០ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៦៤៧០

១៤-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៦៤៧១

១៤-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣២ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៦៤៧២

១៤-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣៣ អនក្រ.តត ស្ដីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៦៤៧៣

១៤-៨-២០០៩ -អនុក្រឹត្យលេខ ១៣៣៤ អនក្រ.តត ស្ដីពីការជូនគ្រឿងឥស្សរិយយស ៦៤៧៤


## III.ការងារបណ្ដាក្រសួង

### ១.ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល


២៥-៨-២០០៩ -ប្រកាសលេខ ៧៨៩ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្សូច ស្កាយ អេនធើប្រាយ បង្កើតរោងចក្រ "ផលិតស្បែកជើង" ៦៥០០

២៥-៨-២០០៩ -ប្រកាសលេខ ៧៩០ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ជុង រ៉ុង អ៊ិនធើណេសិនណល ធីប៉ែកខូ & ស៊ីហ្គារេត គ្រុប បង្កើតរោងចក្រ "ផលិតបារី និង ស៊ីហ្គា" ៦៥០៥

២៥-៨-២០០៩ -ប្រកាសលេខ ៧៩១ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន លីដវីន ស៊ូ (ខេមបូឌា) បង្កើតរោងចក្រ "ផលិតស្បែកជើង" ៦៥១០


### ២.ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


០៣-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៤៩ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិងទទួលស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ជេ ដាប់បែលយូ អិម អ៊ិនដាស្ទ្រី (ខេមបូឌា) គ្រុប ៦៥១៥

# ឃ


០៣-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៥០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួល
ស្គាល់ ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូ ផេត ដើលដ៍** ៦៥១៧

០៤-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៦៧ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ថៃយ.ស៊ី.ភី ម៉ាយគ្រូហ្វាយនែន លីមីធីត** ៦៥១៩

០៤-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៦៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វូ យ៉ាខ អ៊ិនវេសមេន** ៦៥២១

០៤-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៧០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឆាន យាន (ខេមបូឌា) សាយអិនស៍ & ត្រេដ** ៦៥២៣

០៤-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៧១ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេហ្វ អេស ធី អ៊ី & ស៊ី** ៦៥២៥

០៤-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៧៨ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ិចប្រេសសិន អូហ្វ ប៊ីយូធី** ៦៥២៧

០៤-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៧៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្គោលដេន អឺត ផ្លេនីត (ខេមបូឌា) ត្រេឌីង** ៦៥២៩

០៨-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦២៩៩ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ឿន សុខណាន ខនស្ត្រាក់សិន** ៦៥៣១

០៨-១២-២០០៨ -លិខិតបញ្ជាក់លេខ ៦៣០០ ពណ.ចបព ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មនិង ទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អ៊ីតូខេម ខបភើរេសិន** ៦៥៣៣

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

ក- គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍

១- មហាឧបាសកព្រឹទ្ធាចារ្យ ហ៊ុន នាង

២- លោកជំទាវឧកញ៉ា ស៊ុយ សុផាន

ខ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍

១-លោក តេង ហឿន

២-លោក ជា ទ្រី

គ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់មហាសេនា

១- លោក អោង គីមលាង

២- លោក នួន គីមហេង

៣- លោក យិន សំ

៤- លោក ស៊ុំ សុខហេង

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩០៧.៧៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧៩៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ៨ ឆ្នាំ២០០៩

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានតួមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរជ្ជបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

លោក សៅ សារូប

ជា

ឧកញ៉ា

៣៤.០៩០៩.៩៦១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧៨៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

យុន ជីនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៤៦

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឥស្សរជនចំនួន ០៤ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម ÷

- ឯកឧត្តម **ឡុង ទិសារលោ**
- ឯកឧត្តម **អ៊ុច បូរិទ្ធ**
- ឯកឧត្តម **អ៊ុំ ស៊ារ៉ន**
- លោកជំទាវ **ស៊ិន សាតឿន**

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣៩ល.០៩០៩.៩៦២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០០៩*

លេខ: ៣៥៤ ៩ ច.ល

ច្បាប់ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៤៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នាសម័យប្រជុំដំបូងព្រឹទ្ធសភា នីតិកាលទី២ ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១:** -តម្លើងឋានៈជូនឯកឧត្តម **ម៉ៅ សុចន្ថារា** ទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

-តែងតាំងជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី២ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដូចមានរាយនាមខាងក្រោម :

-ឯកឧត្តម **ផាត់ មុនី**

-ឯកឧត្តម **ហុង ពៅ**

**មាត្រា២:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៤ល.០៩០៩.៩៦៣

លេខ: ៧៩៥ ច.ល
បានឃើញ ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- លោកឧកញ៉ា ឌិម ចន្ទឫទ្ធិ ២- លោកឧកញ៉ា សៀ ឫទ្ធី

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- លោក យស់ មុនីរ៉ាត់ ២- លោក ជៀប សួរ

គ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ :

១- ឯកឧត្តម ឃិន ប៊ុនណាង ២- លោក ប៉ែង គង់

៣- លោក គីម អឿន ៤- លោក ឈុន ចាន់ធូ

៥- លោក ហោ ជិនធិរយុទ្ធ ៦- លោក គង់ សំណាង

ឃ- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោកជំទាវ ឈុន ចាន់តាន ២- លោក អាង ពៅ

ង- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា ចំពោះ :

១- លោក ណយ សុខម៉ន ២- លោក ហ៊ាង ប៉ូលី

៣- លោក ង៉ែត សុផលរិទ្ធិ ៤- វរសេនីយទោ ធុត សារ៉ាត់

៥- លោក លី សុខាភិរម្យ ៦- លោក ង៉ូច ស៊ីម៉ុង

៧- លោក លី ឈុន ៨-លោក ឈួរ តារា

៩- លោក ត្នប ឈុនហេង ១០- លោកស្រី មាស ម៉ាលីណែត

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៩.៩៦៤

លេខ: ៧៨៦ ច.ល
ដើម្បីចម្លងចែក
ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩ រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៩
រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពុហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

## គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

## ឯកឧត្តម នាយឧត្តមសេនីយ៍ ឡុល គឿន

៣៧៧.០៩០៧.៩៦៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ: ៧០៥.ច.ល
សម្រាប់ចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ០៨ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៥០

យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- ឯកឧត្តម ឈុន ស៊ីរុន
២- ឯកឧត្តម គង់ វិបុល
៣- លោកជំទាវ សុភ័ក្ត្រ ថាវី
៤- ឯកឧត្តម សរ សិទ្ធិ
៥- ឯកឧត្តម ផៃ ប៊ុនឈឿន

ខ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

១- លោក ឧកញ៉ា ហាន់ ឃាង
២- លោកជំទាវ ឧកញ៉ា សោម សុផល
៣- លោកជំទាវ ឧកញ៉ា សាត ណាវី
៤- លោកជំទាវ ឧកញ៉ា គូ គីមឡុង
៥- លោកជំទាវ ឧកញ៉ា ជា សុវណ្ណនី
៦- លោកជំទាវ សម លក្ខិណា
៧- លោកជំទាវ អៀង វុឌ្ឍី
៨- លោកស្រី លីម លីឡេង

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

១- ឯកឧត្តម ហ៊ុយ ពិសិដ្ឋ
២- ឯកឧត្តម ក្ខុល សំអុល
៣- ឯកឧត្តម កែវ សុទ្ធា
៤- លោកឧកញ៉ា ទ្រី ហេង
៥- ឯកឧត្តម ជួន សុវណ្ណ
៦- ឯកឧត្តម អ៊ុក ដាមរី
៧- ឯកឧត្តម ឃុន វុធ
៨- ឯកឧត្តម ម៉ក់ ពេជ្ររិទ្ធ
៩- ឯកឧត្តម ជា ចន្ថា
១០- ឯកឧត្តម អ៊ំ សារិត
១១- ឯកឧត្តម សារ៉ាយ ឆួន
១២- ឯកឧត្តម ថោង សំអាត
១៣- លោក ហេង ឆៀម
១៤- ឯកឧត្តម ហាច រតនៈ

ឃ-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេនា** ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១- ឯកឧត្តម | ស្លួស | អន្ថារ៍ | ២- ឯកឧត្តម | ជីវ | សុខហាត់ |
| ៣- លោកជំទាវ | ហៅឡែន | អ៊ុត ដាមរី | ៤- លោកវរសេនីយ៍ឯក | ជា | ប៊ុនថុល |
| ៥- លោកវរសេនីយ៍ឯក | សឿន | អួន | ៦- លោកវរសេនីយ៍ទោ | ឌុច | ដារ៉ា |
| ៧- ឯកឧត្តម | រួន | រត្ន័ជាសនា | ៨- ឯកឧត្តម | ថោង | លីម |
| ៩- ឯកឧត្តម | ម៉ត់ | ជីតូ | ១០- ឯកឧត្តម | ជិន | ចាយ |
| ១១- ឯកឧត្តម | អ៊ុក | គឹមលេខ | ១២- ឯកឧត្តម | រស់ | នឹមសារួន |
| ១៣- ឯកឧត្តម | ឯក | ត្រិត្យ | ១៤- លោកវរសេនីយ៍ឯក | គង់ | ចាន់រ័ត្ន |
| ១៥- លោកវរសេនីយ៍ឯក | ម៉ា | ឧត្តម | ១៦- លោក | កែវ | ម៉ានី |
| ១៧- ឯកឧត្តម | ហ៊ី | សុជាតិ | ១៨- លោក | រួយ | ឈុនលី |

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១- ឯកឧត្តម | រួន | ចាន់ដារ៉ារិទ្ធិ | ២- លោក | សុខ | អឿន |
| ៣- លោក | ឈឿន | សុចិត្ត | ៤- លោក | ជា | ប៊ុនធឿន |
| ៥- លោក | អ៊ូ | ឈាង | ៦- លោកវរសេនីយ៍ឯក | ជា | ជឿន |
| ៧- លោកវរសេនីយ៍ឯក | លាង | ចិន្ត្រាធរ | ៨- លោកវរសេនីយ៍ទោ | ចាន់ | ម៉ាន់ធឿន |
| ៩- លោកវរសេនីយ៍ទោ | អ៊ុង | ផាន់ណា | ១០- លោកវរសេនីយ៍ទោ | ព្រែង | ព្រាលីង |
| ១១- លោក | នួន | សាន | ១២- លោក | នួន | សុធិមន្ត |
| ១៣- លោក | ផេង | សុភាគ | ១៤- លោកវរសេនីយ៍ទោ | ស៊ុត | ដារ៉ុម |
| ១៥- លោកវរសេនីយ៍ទោ | អ៊ុំ | ម៉ូនី | ១៦- លោកវរសេនីយ៍ទោ | ប៊ុល | សៀង |
| ១៧- លោកវរសេនីយ៍ត្រី | សុខ | រត្ន័ | ១៨- លោកវរសេនីយ៍ត្រី | ហ៊ុយ | ហ៊ីន |
| ១៩- លោកវរសេនីយ៍ត្រី | ម៉ម | ឡឿន | ២០- លោកវរសេនីយ៍ត្រី | ភឿង | ប្ញុរ៉ា |
| ២១- លោកវរសេនីយ៍ត្រី | សែម | ស៊ុនលី | ២២- លោកវរសេនីយ៍ទោ | ខៀវ | សុខចន្ទ័សុធា |
| ២៣- លោក | លី | ណារិទ្ធ | ២៤- លោកឧត្តមសេនីយ៍ត្រី | ខៀវ | ចាន់រ៉ា |
| ២៥- លោក | ពៅ | សុខន | ២៦- លោកឧត្តមសេនីយ៍ត្រី | គឿន | តិរម្យ |
| ២៧- លោក | គង់ | នេង | ២៨- លោក | សៀង | ចណ្ណរ៉ៃ |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

ច.គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ចំពោះ :

១- លោក ឈឿន ប៊ុណ្ណារក្ស័
២- លោកវរសេនីយ៍ទោ យិន ប្រសិទ្ធ
៣- លោកវរសេនីយ៍ត្រី យន់ សម្បត្តិ
៤- លោកវរសេនីយ៍ត្រី រ៉េហា សំអាត
៥- លោកវរសេនីយ៍ត្រី គួច គ្រិត
៦- លោកវរសេនីយ៍ត្រី ឃឿន ឌីណា
៧- លោកវរសេនីយ៍ឯក អ៊ុំ ចណ្ណា
៨- លោកវរសេនីយ៍ឯក យិន សុផល
៩- លោកវរសេនីយ៍ឯក អ៊ុន សុផល
១០- លោកវរសេនីយ៍ឯក ស៊ូ ប៊ុនរាជ
១១- លោក អៀង ប៊ុនហាត់
១២- លោក លឹម ចន្ទ័ប៊ុនតែង
១៣- លោកវរសេនីយ៍ទោ ហ៊ឹម សុឡី
១៤- លោកវរសេនីយ៍ត្រី ខៀវ សំណាង
១៥- លោកវរសេនីយ៍ត្រី ស៊ិន សម្បត្តិ
១៦- លោកស្រី សាន់ណារ៉ា ឡុងឌី
១៧- លោកវរសេនីយ៍ឯក ម៉ៃ ស៊ីខេងវ៉ាន់ឌី

ឆ.គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** ចំពោះ :

១- លោកវរសេនីយ៍ទោ សុខ សេរីវុធ
២- លោកវរសេនីយ៍ត្រី ឈុន ថា
៣- លោកអនុសេនីយ៍ឯក ហួត តឿ
៤- លោកអនុសេនីយ៍ឯក សេង សាន្ត
៥- លោកអនុសេនីយ៍ឯក ខៀវ សុផាត
៦- លោកអនុសេនីយ៍ឯក ម៉ិច សំបូរ
៧- លោកវរសេនីយ៍ឯក ប៉ាល់ ណារិទ្ធ
៨- លោកអនុសេនីយ៍ឯក ខៀវ ចណ្ណៈ
៩- លោកអនុសេនីយ៍ឯក លី សរ
១០- លោកអនុសេនីយ៍ឯក ប៉ូ ប៉ៃលិន
១១- លោកស្រីវរសេនីយ៍ឯក អ៊ុំ លក្ខិណា
១២- លោកវរសេនីយ៍ឯក ចន្ទ័ សុខា
១៣- លោកវរសេនីយ៍ត្រី ទួន ផាត
១៤- លោកវរសេនីយ៍ត្រី មាស ណុន
១៥- លោកវរសេនីយ៍ទោ អ៊ូ សុទ្ធារ៉ា
១៦- លោកវរសេនីយ៍ត្រី គួប គីមលី
១៧- លោកវរសេនីយ៍ទោ ជា សុគន្ធា
១៨- លោកវរសេនីយ៍ត្រី សេម សឿន
១៩- លោកវរសេនីយ៍ឯក ឈឹម គា
២០- លោក អួន ប៊ុនហាត់
២១- លោក លឹម ឡុង
២២- លោក ខាត់ សាត
២៣- លោកវរសេនីយ៍ត្រី ចាន់ សិទ្ធា
២៤- លោកអនុសេនីយ៍ឯក កែប គិត

ព្រះហស្តលេខា និងព្រះរាជលញ្ចករ

នរោត្តម សីហមុនី

៣៤ល.០៩០៩.៩៦៦

លេខៈ ៩០៤ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៥១

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

១-ឯកឧត្ដម ឈិត គីមយ៉ាត
២-ឯកឧត្ដម សុក ស៊ីផាន់ណា
៣-ឯកឧត្ដម លី វ៉ាន់ហុង
៤-ឯកឧត្ដម កៅ វុទ្ធី
៥-ឯកឧត្ដម ហ៊ី ប៊ុនគីម
៦-លោក ហេង សុខុម

នូវ

គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ.ល.០៩០៩.៩៦៧

លេខ: ៧៩៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្ដីការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

នស/រកត/០៨០៩/៩៥២

# ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

លោក គួជ ម៉េងលី

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

៣រល.០៩០៩.៩៦៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៧៥៩៥ច.ល
ជំនួសម្រង់ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ [illegible] ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៥៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រត្តនខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម យឹម ឈុលសន    ២- លោកឧកញ៉ា ឆាយ គួង

ខ-គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

១- ឯកឧត្តម សុខ ឡេង    ២- Mr. Wang Yeong Khang

៣- Mr. Sura Veerakiatikul    ៤- វរសេនីយ៍ទោ យូ សុធារិទ្ធ

គ - គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- លោក ងិត សុបិន    ២- លោក សរ គឹមណាត

៣- លោក គោ ថៃ    ៤- លោក យន សុផាន់

៥-លោក ស្រ៊ុន សាលី    ៤- លោក ម៉ុត ជី

៧- លោក ម៉ុត ចិន្តា    ៨- លោក ម៉ែន ឌិន

៩- លោកស្រី កែវ សុគន្ធា    ១០- លោកស្រី ហាន់ ម៉ាន់លី

១១- លោក ឌួន គឹមហេង    ១២- លោក ផាន់ ម៉េងឃឿន

១៣-លោក ឯត សំឡូ    ១៤- លោក ឈាង ឡាត់

ឃ- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ ចំពោះ :

១- Mrs. Marivic De Leon-Escaro    ២- Mr. Shuji Matsuoka

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩០៧.៧៦៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ. ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩

លេខ: [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
[illegible]អគ្គលេខាធិការរងរាជរដ្ឋាភិបាល

[illegible] ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **ឆេព ម៉ុន្នី** ជាទីប្រឹក្សាអមក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានឋានៈស្មើអនុរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។.

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

លេខ: ៤០៣ ច.ល
៣៧.០៩០៩.៩៧០
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ២០០៩
*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩*
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុន ចាន់ថុល**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៧៥៥

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្ដម | ធេព ចន | ២- | ឯកឧត្ដម | ហេង តៃគ្រី |

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១- | ឯកឧត្ដម | ចៅ តុល | ២- | ឯកឧត្ដម | ឡាយ ម៉េងឃីន |
| ៣- | ឯកឧត្ដម | ខួច សម្បត្តិ | ៤- | ឯកឧត្ដម | ប៊ិច សុវណ្ណ |
| ៥- | ឯកឧត្ដម | ឈួន សុធី | ៦- | ឯកឧត្ដម | ប៊ិត គីមហុង |
| ៧- | លោក | យឹម គាង | ៨- | លោក | លុយ ធៀម |
| ៩- | ឯកឧត្ដម | អ៊ូ រ៉ាស៊ី | ១០- | ឯកឧត្ដម | ឈាង រ៉ា |
| ១១- | លោក | សេង គីមយន | ១២- | លោក | វ៉ែក គំនិត |
| ១៣- | លោកឧកញ៉ា | សុខ សីលា | | | |

គ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** ចំពោះ :

| | | | | | |
|---|---|---|---|---|---|
| ១- | លោក | លឹម ថៃគាង | ២- | លោក | ធូត សារ៉ាវុធ |
| ៣- | ឯកឧត្ដម | មាស សារិន | ៤- | លោក | ជន យាងលី |
| ៥- | ឯមឧត្ដម | ស៊ឹម ចណ្ណា | ៦- | ឯកឧត្ដម | ធី ណេង |
| ៧- | ឯកឧត្ដម | ហ៊ុង ចិណ្ឌុល | ៨- | ឯកឧត្ដម | លឹម ឡេង |
| ៩- | លោកឧកញ៉ា | ប៊ុន សចំ | ១០- | លោក | ម៉ុំ ជោគ |
| ១១- | លោក | យស សុខា | ១២- | លោក | ហេង សុបញ្ញា |
| ១៣- | លោក | សុខ ថន | ១៤- | លោក | ចឡូ ចាន់ |
| ១៥- | លោក | ហេង សុយន | | | |

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពរល.០៩០៥.៧៧១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៥

លេខ: ៥០៦ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០០៥
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហនាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោក អ៊ឹង សុចិត្ត

ជា

ឧកញ៉ា

ចរល.០៩០៩.៩៧២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩

លេខ: ៩០២ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ៨ ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៩៥៧

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់ **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ត្រូវបានតែងតាំង :

១- **ឯកឧត្ដម សួន ផេង** ជាទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២- **ឯកឧត្ដម ចៅ ជីវអាន** ជាទីប្រឹក្សាសម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា ២** : សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា និងសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩០៩.៩៧៣

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៩*

លេខ: ៧០០ ច.ល

ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ២០០៩

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៩/៧៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំពេញអង្គរដ្ឋសភាលើកទី១ នីតិកាលទី៤ នាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការបោះឆ្នោតជ្រើសតាំងថ្នាក់ដឹកនាំរដ្ឋសភា និងសមាសភាពរាជរដ្ឋាភិបាល នីតិកាលទី៤
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា** នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំង :

| | |
|---|---|
| ១- ឯកឧត្តម **ប៉ាង ប៉ាន់ថា** | ជាទីប្រឹក្សាសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។ |
| ២- ឯកឧត្តម **អ៊ិត នារ:** | ជាជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។ |
| ៣- ឯកឧត្តម **ហេង បូរ៉ា** | ជាជំនួយការសម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា នីតិកាលទី៤មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។ |

មាត្រា ២ : សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា និងសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩០៩.៩៧៤

*ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ សីហា ឆ្នាំ ២០០៨*

លេខៈ ៧០១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ៨ ៗ ឆ្នាំ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៣៧៩.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ជំរឿនសមាគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងផែនការ
- បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៥/០១៥ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្ថិតិ
- បានឃើញអនុក្រឹត្យលេខ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ០៩ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងកិច្ចដំណើរការរបស់ប្រព័ន្ធស្ថិតិជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០០៩

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលដៅកំណត់ពីជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ ÷

- ទទួលបាននូវព័ត៌មានសេដ្ឋកិច្ចស្តីពីសហគ្រាសគ្រប់វិស័យ សម្រាប់បម្រើអ្នកប្រើប្រាស់នានា
- ធ្វើជាទិន្នន័យមូលដ្ឋាន សម្រាប់រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងគម្រោងនានា ដើម្បីជំរុញកិច្ចអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងសុខុមាលភាពប្រជាជន។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្ត លើគ្រប់អង្គភាពសេដ្ឋកិច្ចទាំងអស់ ដែលស្ថិតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែអង្គភាពកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**មាត្រា៤.-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះ មាននិយមន័យដូចតទៅ ÷

- សហគ្រាស សំដៅដល់អង្គភាពអាជីវកម្ម ឬផ្នែកមួយនៃអង្គភាពអាជីវកម្ម ដែលមានទីតាំងមួយជាក់លាក់ ហើយមានសកម្មភាពផលិតកម្មតែមួយ ឬមានសកម្មភាពផលិតកម្មសំខាន់ ដែលបង្កើតបានតម្លៃបន្ថែមមួយផ្នែកធំ
- ជំរឿនសហគ្រាស សំដៅដល់ជំរឿនផ្នែកសេដ្ឋកិច្ច ដែលអនុវត្តទៅលើអង្គភាពសេដ្ឋកិច្ច មានជាអាទិ៍ សហគ្រាសគ្រប់ប្រភេទ រោងចក្រ សហគ្រាសរដ្ឋ ឯកជន សិប្បកម្ម អាជីវកម្ម លក់ដុំ លក់រាយ និងសេវាកម្ម ផ្សេងៗ។

## ជំពូកទី២

## កាលបរិច្ឆេទ

**មាត្រា៥.-**

កាលបរិច្ឆេទជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជា កំណត់នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១១។

## ជំពូកទី៣

## យន្តការ និងនីតិវិធី

**មាត្រា៦.-**

បង្កើតគណៈកម្មាធិការជាតិជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១១ ដែលមានសមាសភាព

ដូចខាងក្រោម ÷

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងផែនការ | ប្រធាន |
| - រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| - រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| - រដ្ឋលេខាធិការក្រសួងផែនការ | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| - រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី | សមាជិក |
| - រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| - អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា | សមាជិក |
| - ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា | សមាជិក |
| - អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ | លេខាធិការ ។ |

**មាត្រា៧.-**

គណៈកម្មាធិការជាតិជំរឿនសហគ្រាសនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០១១ មានគណៈកម្មការបច្ចេកទេសជំរឿនសហគ្រាស គណៈកម្មាធិការឃោសនាជំរឿនសហគ្រាស និងគណៈកម្មាធិការជំរឿនសហគ្រាសរាជធានី ខេត្ត ដែលកំណត់ដោយសេចក្តីសម្រេច ។

**មាត្រា៨.-**

គណៈកម្មាធិការជាតិជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០១១ មានភារកិច្ច÷

ក- ណែនាំ និងអនុម័តរាល់កិច្ចការទូទៅដែលពាក់ព័ន្ធនឹងជំរឿនសហគ្រាស ។

ខ- រៀបចំ និងបង្កើតគណៈកម្មការបច្ចេកទេសជំរឿនសហគ្រាស និងគណៈកម្មាធិការឃោសនាជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជា មានទីស្នាក់ការនៅក្រសួងផែនការ និងស្ថិតក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងផែនការ សម្រាប់អនុវត្តផ្ទាល់រាល់ការងារបច្ចេកទេសក្នុងការជំរឿនសហគ្រាស ។

គ- រៀបចំ និងបង្កើតគណៈកម្មាធិការជំរឿនសហគ្រាស រាជធានី ខេត្ត ។

ឃ- ចាត់តាំងមន្ត្រីឱ្យចូលរួមជំរឿនសហគ្រាស តាមការស្នើសុំពីគណៈកម្មការបច្ចេកទេសជំរឿនសហគ្រាស ។

ង- ប្រជុំការងារយ៉ាងតិច ៦ ( ប្រាំមួយ ) ខែម្តង តាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ ឬអនុប្រធានគណៈកម្មាធិការ នៅពេលដែលប្រធានគណៈកម្មាធិការអវត្តមាន ។

ច- ត្រូវធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពីការប្រព្រឹត្តទៅ និងលទ្ធផលនៃជំរឿនសហគ្រាស ។

**មាត្រា៩.-**

គណៈកម្មាធិការជាតិជំរឿនសហគ្រាស នៅព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

គណៈកម្មការបច្ចេកទេសជំរឿនសហគ្រាស មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

គណៈកម្មាធិការឃោសនាជំរឿនសហគ្រាស មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងផែនការ ។

គណៈកម្មាធិការជំរឿនសហគ្រាសរាជធានី ខេត្ត មានសិទ្ធិប្រើប្រាស់ត្រារបស់រាជធានី ខេត្ត ។

**មាត្រា១០.-**

ជំរឿនសហគ្រាស ត្រូវមានដំណាក់កាលដូចតទៅ ÷

១- កិច្ចប្រតិបត្តិការដំបូងរបស់ការជំរឿនមាន ÷

- ការរៀបចំផែនទី
- ការរាប់ និងធ្វើបញ្ជីអង្គភាពសេដ្ឋកិច្ច
- ការធ្វើអង្កេត និងជំរឿនសាកល្បង ។

២- ការធ្វើសម្ភាសអង្គភាពសេដ្ឋកិច្ចសម្រាប់ការជំរឿន ។

៣- កិច្ចប្រតិបត្តិការចុងក្រោយរបស់ការជំរឿនមាន ÷

- ការធ្វើអង្កេតសម្រាប់ការវាយតម្លៃលើការជំរឿនដែលបានធ្វើហើយ
- ការធ្វើអង្កេតផ្សេងទៀតក្នុងករណីចាំបាច់ ។

**មាត្រា១១.-**

អគ្គនាយកវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ជាអគ្គនាយកជំរឿនសហគ្រាស និងត្រូវមានមន្ត្រីបច្ចេកទេស មន្ត្រីរដ្ឋបាលនៃវិទ្យាស្ថានជាតិស្ថិតិ និងមន្ទីរផែនការរាជធានី ខេត្ត ជួយរាល់ការងារក្នុងការជំរឿន ។

**មាត្រា១២.-**

មន្ត្រីបំពេញការងារជំរឿនរួមមាន អ្នកត្រួតពិនិត្យការសម្ភាស អ្នកសម្ភាសស្រង់យកព័ត៌មាន និងភ្នាក់ងារជំនួយការដល់កិច្ចសហប្រតិបត្តិការជំរឿន ត្រូវចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងផែនការ តាមការស្នើសុំរបស់អគ្គនាយក

ជំរឿនសហគ្រាស ។ ការចាត់ចែងនេះអនុវត្តបានតែក្នុងអំឡុងពេលជំរឿនតែប៉ុណ្ណោះ ។

**មាត្រា១៣.-**

រដ្ឋមន្ត្រីក្រសួងផែនការ មានសិទ្ធិស្នើសុំមន្ត្រីពីបណ្តាក្រសួង ស្ថាប័នសាធារណៈ និងប្រជាពលរដ្ឋ ដើម្បីសហការជួយធ្វើកិច្ចការជំរឿនសហគ្រាស ។

**មាត្រា១៤.-**

ម្ចាស់អង្គភាពសេដ្ឋកិច្ច ត្រូវសហការ និងអនុញ្ញាតឱ្យមន្ត្រីបំពេញការងារជំរឿន ដែលបង្ហាញលិខិតបេសកកម្មផ្លូវការ បានចូលក្នុងអង្គភាពសេដ្ឋកិច្ច លំនៅឋាន ឬទីកន្លែងរបស់ខ្លួន ក្នុងគោលដៅនៃការជំរឿន និងអនុញ្ញាតឱ្យមន្ត្រីទាំងនោះ អាចលាបពណ៌ បិទអក្សរ បិទសញ្ញា ឬលេខសម្គាល់នៅតាមកន្លែងចាំបាច់ សម្រាប់បម្រើដល់ការងារជំរឿនសហគ្រាស ។

**មាត្រា១៥.-**

រដ្ឋមន្ត្រីក្រសួងផែនការ អាចប្រកាសចាត់តាំងអ្នកគ្រប់គ្រងជំរឿនសហគ្រាស តាមទីកន្លែងដែលមានលក្ខណៈពិសេសដូចខាងក្រោម÷

ក- អ្នកគ្រប់គ្រងសហគ្រាសសាធារណៈ និងឯកជន ។

ខ- អ្នកគ្រប់គ្រងសណ្ឋាគារ អ្នកគ្រប់គ្រងផ្ទះសំណាក់ នាយកមជ្ឈមណ្ឌលសម្រាកកាយ ។

គ- អ្នកចាត់ការក្នុងគ្រឹះស្ថានពាណិជ្ជកម្ម អ្នកចាត់ការក្នុងគ្រឹះស្ថានឧស្សាហកម្ម ។

ឃ- អ្នកគ្រប់គ្រងស្ថានីយ៍រថភ្លើង ព្រលានយន្តហោះ ចំណតរថយន្ត និងកំពង់ផែ ។

ង- នាយកមន្ទីរពេទ្យ ។

ច- អ្នកគ្រប់គ្រងអង្គភាពសេដ្ឋកិច្ចផ្សេងៗទៀតដែលចាំបាច់ ។

**មាត្រា១៦.-**

មន្ត្រីដែលគ្មានកាតព្វកិច្ចទទួលខុសត្រូវក្នុងការជំរឿន មិនមានសិទ្ធិត្រួតពិនិត្យរាល់សៀវភៅ បញ្ជី ឬសំណៅកត់ត្រា ដែលបានធ្វើឡើងដោយមន្ត្រីបំពេញការងារជំរឿនបានឡើយ ។

## ជំពូកទី៤

## ប្រភពធនធាន

**មាត្រា១៧.-**

ជំរឿនសហគ្រាសមានប្រភពធនធានដូចតទៅ ÷

- ថវិកាជាតិ
- ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍ
- អំណោយពីសប្បុរសជននានា

ប្រភពធនធានផ្សេងៗ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា១៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ និងសមាជិកគណៈកម្មាធិការជាតិ ដូចក្នុងមាត្រា ៦ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ៧ ឆ្នាំ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១៩*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៨/០២០ , ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៩
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក. ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ. បក. ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក. ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៨ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៤០.០០០ លានរៀល (សែសិបពាន់លានរៀលគត់) ពីជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៦០ (ការទិញ) ចំនួន ១៦.០០០ លានរៀល និង មកជំពូក ៦៥ (ឧបត្ថម្ភកធន និង ជំនួយសង្គម) ចំនួន ២៤.០០០ លានរៀល របស់ក្រសួងសុខាភិបាល សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៩ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះតាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ទិញឱសថ និង បរិក្ខារពេទ្យសុខភាពបន្ថែម ក្នុងឆ្នាំ ២០០៩ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ ៧ ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីគោរពជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី ជាអ្នកចុះហត្ថលេខា**

**គាត ឈន់**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតគណៈកម្មាធិការ ដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ បើកបរលើបណ្តាញផ្លូវនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលគ្រប់គ្រងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានគោលបំណង ៖

- ដាក់ចេញនូវវិធានការទប់ស្កាត់រាល់ការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- គ្រប់គ្រងស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ស្ថិតនៅតាមបណ្តាញផ្លូវ ដែលគ្រប់គ្រងដោយក្រសួងសាធារណការ និងដឹកជញ្ជូន
- ទប់ស្កាត់ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដោយសកម្មភាពដឹកជញ្ជូនលើសទម្ងន់ ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឱ្យបានស្ថិតស្ថេរយូរអង្វែងស្របតាមបច្ចេកទេសនៃការស្ថាបនាផ្លូវថ្នល់
- ចាត់វិធានការក្នុងការបង្រ្កាប និងទប់ស្កាត់បទល្មើសដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ឱ្យបានទាន់ពេលវេលា ។

**មាត្រា ៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសកម្មភាពដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងការថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## រចនាសម្ព័ន្ធ និងសមាសភាព

**មាត្រា ៤ .-**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់មានរចនាសម្ព័ន្ធ ដូចតទៅ៖

១- គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ។
២- គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ។
៣- អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ។
៤- លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ។

**មាត្រា ៥ .-**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៥- | មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៦- | អភិបាលរាជធានី អភិបាលខេត្ត | សមាជិក |
| ៧- | ប្រធាន គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ | សមាជិកអចិន្ត្រៃយ៍ |

ប្រធានគណៈកម្មាធិការ ដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ អាចអញ្ជើញ

តំណាងក្រសួង ស្ថាប័ន និងអភិបាលរាជធានី អភិបាលខេត្តពាក់ព័ន្ធ ចូលរួមប្រជុំតាមការចាំបាច់។ គណៈកម្មាធិការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ៦ .-**

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ត្រូវតែងតាំងដោយសេចក្តីសម្រេច របស់ប្រធានគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់។ សមាជិកគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍អាចមានការផ្លាស់ប្តូរតាមការចាំបាច់។

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- | តំណាងរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- | តំណាង អគ្គនាយកដ្ឋានសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- | តំណាង អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៤- | តំណាង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៥- | តំណាង អាជ្ញាធរដែនដីរាជធានី ខេត្ត | សមាជិក |
| ៦- | តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- | តំណាង អគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨- | ប្រធាន មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត | សមាជិក |

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ មានទីតាំងនៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន។

**មាត្រា ៧ .-**

អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- | តំណាង មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត | មានឋានៈស្មើនឹងអនុប្រធានមន្ទីរ |
| ២- | តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន | មានឋានៈស្មើនឹងអនុប្រធានការិយាល័យ |
| ៣- | តំណាង សាលារាជធានី ខេត្ត | មានឋានៈស្មើនឹងប្រធានការិយាល័យខេត្ត |
| ៤- | តំណាង ស្នងការនគរបាលរាជធានី ខេត្ត | មានឋានៈស្មើនឹងប្រធានការិយាល័យខេត្ត |
| ៥- | តំណាង មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត | មានឋានៈស្មើនឹងប្រធានការិយាល័យខេត្ត |

៦- ក្នុងករណីចាំបាច់ អាចស្នើសុំមន្ត្រីជំនាញមួយចំនួនតាមតំណាងខាងលើ ដើម្បីជាជំនួយការ។

ការតែងតាំងសមាសភាពអង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់ ត្រូវកំណត់ដោយប្រកាសរបស់ប្រធានគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកលើសទម្ងន់កម្រិតកំណត់ តាមការស្នើសុំរបស់ប្រធានគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍។

**មាត្រា ៨ .-**

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម :

១- ប្រធាន ដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន។

២- អនុប្រធាន ដែលមានឋានៈស្មើប្រធានការិយាល័យ។

៣- សមាជិកមួយចំនួន តាមតម្រូវការចាំបាច់ ។

## ជំពូកទី ៣
## តួនាទី និងភារកិច្ច

**មាត្រា ៩ .-**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់មានភារកិច្ច ដូចតទៅ ÷

- រៀបចំ និងដាក់ចេញវិធានការទប់ស្កាត់រាល់សកម្មភាពដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំ និងដាក់ចេញនូវគោលការណ៍អនុវត្តការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ នៅលើបណ្តាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួលតាមដាននិងត្រួតពិនិត្យការអនុវត្តន៍ការងាររបស់គណៈកម្មាធិការសម្របសម្រួល អចិន្ត្រៃយ៍
- រាយការណ៍ជូនរាជរដ្ឋាភិបាល អំពីសកម្មភាពត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១០ .-**

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ មានភារកិច្ចដូចតទៅ ÷

- រៀបចំសេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា របស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំសមាសភាពរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំ កំណត់ទីតាំងរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ របស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដើម្បីដាក់ក្នុងកញ្ចប់ថវិកាក្រសួងសាធារណការ និងដឹកជញ្ជូន
- សម្របសម្រួលនិងជំរុញសកម្មភាពត្រួតពិនិត្យ របស់អង្គភាពត្រួតពិនិត្យ និងស្ថានីយថ្លឹងទម្ងន់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- កំណត់កម្មវិធីការងាររបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បែងចែកតួនាទី និងភារកិច្ចរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- ទំនាក់ទំនង និងសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ណែនាំការផាកពិន័យតាមកំហុសជាក់ស្តែងដោយអនុលោមតាមមាត្រា ៨៤ នៃច្បាប់ចរាចរណ៍ផ្លូវគោក និងបទប្បញ្ញត្តិផ្សេងៗទៀតជាធរមាន
- អាចប្រើប្រាស់មន្ត្រីជំនាញ តាមសមត្ថភាពរៀងៗខ្លួន តាមពេលវេលានិងទំហំការងារចាំបាច់
- បង្កើតក្រុមត្រួតពិនិត្យចល័តពិសេសសំរាប់បេសកកម្មមួយរយៈ ដើម្បីធ្វើការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ នៅតាមបណ្តាញផ្លូវ ដែលពុំមានស្ថានីយថ្លឹងយានយន្ត
- គ្រប់គ្រងប្រាក់ដែលបានមកពីការផាកពិន័យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- ត្រូវកំណត់បទបញ្ជាផ្ទៃក្នុងសម្រាប់អនុវត្តការងារ ឱ្យមានប្រសិទ្ធភាព
- អនុវត្តភារកិច្ចផ្សេងទៀត ដែលគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូន ប្រគល់ជូន។

**មាត្រា ១១ .-**

តួនាទី និងភារកិច្ចរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៤
## ស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងឯកសណ្ឋាន

**មាត្រា ១២ .-**

ស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដែលបានបង្កើតឡើងនៅតាមបណ្តាញផ្លូវជាតិត្រូវមានឈ្មោះ ទីតាំងជាក់លាក់ និងមានមន្ត្រីបម្រើការងារក្នុងស្ថានីយនីមួយៗឱ្យបានសមស្របតាមការកំណត់ ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

ចំនួនស្ថានីយថ្លឹងយានយន្ត ឈ្មោះស្ថានីយ និងទីតាំងស្ថានីយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ១៣ .-**

ក្នុងពេលប្រតិបត្តិការងារនៅតាមស្ថានីយថ្លឹងទម្ងន់ និងធ្វើសកម្មភាពចល័តត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មន្ត្រីត្រួតពិនិត្យដែលត្រូវបានចាត់តាំងឱ្យបំពេញការងារ ត្រូវស្លៀកពាក់ឯកសណ្ឋាន និង មានប័ណ្ណសម្គាល់ខ្លួន ។ ចំពោះមន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថត្រូវស្លៀកពាក់ឯកសណ្ឋានរបស់ខ្លួន ។ ឯកសណ្ឋាន និង ប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីស្ថានីយថ្លឹងយានយន្តដឹកជញ្ជូន លើសទម្ងន់កម្រិតកំណត់នៅតាមស្ថានីយថ្លឹងនីមួយៗ និងមន្ត្រីក្រុមត្រួតពិនិត្យចល័តពិសេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៥
## អំពីថវិកា

**មាត្រា ១៤ .-**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានខ្ទង់ថវិកាដោយឡែកដែលជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

ប្រភពធនធាន និងថវិការបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យ យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ រួមមាន ÷

- ថវិកាជាតិ ។
- ហិរញ្ញប្បទានសហប្រតិបត្តិការ ពីក្នុង និងក្រៅប្រទេស ដែលផ្តល់ដោយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ។

**មាត្រា ១៥ .-**

ប្រាក់ដែលទទួលបានពីការផាកពិន័យ ត្រូវបង់ចូលថវិការដ្ឋចំនួន៦០% និងប្រាក់៤០% ត្រូវបានអនុញ្ញាតជារង្វាន់

ដល់ភ្នាក់ងារមានសមត្ថកិច្ច ដែលបានខិតខំអនុវត្តភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៦ .-**

អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់អតិបរមា និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី អភិបាលខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
